**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**
លេខ : ២៥៦៤ ឋប

ថ្ងៃអង្គារ ១០កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣

# សេចក្ដីប្រកាសព័ត៌មាន
# ស្ដីពី
# សន្និសីទស្ដីពីការជំរុញអភិបាលកិច្ចនិងបច្ចេកវិទ្យាឌីជីថល ក្រោមប្រធានបទ "ការជំរុញបរិវត្តកម្មឌីជីថលនៅក្នុងវិស័យសាធារណៈ"

នាព្រឹកថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ នៅបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា ឯកឧត្តម **ជា វ៉ាន់ដេត** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (**ក.ប.ទ.**) និងជាប្រធានគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល (**គ.រ.ឌ.**) បានអញ្ជើញជាអធិបតីក្នុងពិធីបើកសន្និសីទស្ដីពី "ការជំរុញអភិបាលកិច្ចនិងបច្ចេកវិទ្យាឌីជីថល" ហៅកាត់ថា សន្និសីទ GovTech ជាលើកដំបូង ក្រោមប្រធានបទ "ការជំរុញបរិវត្តកម្មឌីជីថលនៅក្នុងវិស័យសាធារណៈ" ដែលមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំ មន្ត្រីបច្ចេកទេសពីក្រសួង ស្ថាប័ន តំណាងដៃគូអភិវឌ្ឍន៍ អង្គការសមាគម និងវិស័យឯកជន ដែលមានចំនួនសរុបប្រមាណ ២០០ នាក់។

នៅក្នុងឱកាសនោះ ឯកឧត្តមបណ្ឌិត **សេង សុភាព** ប្រធានបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា (**ប.ប.ឌ.**) បានថ្លែងមតិស្វាគមន៍ និងជម្រាបជូនអង្គពិធីទាំងមូលអំពីសកម្មភាពការងាររបស់ **ប.ប.ឌ.** ក្នុងការចូលរួមចំណែកក្នុងការកសាងរដ្ឋាភិបាលឌីជីថល តាមរយៈការបណ្ដុះបណ្ដាលមន្ត្រីរាជការលើជំនាញឌីជីថលចាំបាច់ ជំនាញបច្ចេកទេស ជំនាញភាពជាអ្នកដឹកនាំបរិវត្តកម្មឌីជីថល និងការរៀបចំសិក្ខាសាលា វេទិកា និងសន្និសីទសម្រាប់មន្ត្រីរាជការសិក្សាស្វែងយល់ អនុវត្ត និងផ្លាស់ប្ដូរបទពិសោធការងារពាក់ព័ន្ធនឹងការអភិវឌ្ឍប្រព័ន្ធឌីជីថលសម្រាប់ផ្ដល់សេវាជូនប្រជាពលរដ្ឋនៅតាមវិស័យជំនាញរបស់ក្រសួង ស្ថាប័ន។ ជាក់ស្ដែង សន្និសីទ GovTech នាពេលនេះ មានគោលបំណងសំខាន់ចំនួន៣ ដូចជា (១)ផ្ដល់វេទិកាសម្រាប់មន្ត្រីបច្ចេកទេសឌីជីថលក្នុងការចែករំលែកបទពិសោធ ឧត្ដមានុវត្តន៍ និងករណីសិក្សាពាក់ព័ន្ធនឹងអភិបាលកិច្ចនិងបច្ចេកវិទ្យាឌីជីថល (២)ជំរុញនិងបង្កើនភាពស្និទស្នាលនិងដៃគូសហការ និង (៣)កំណត់អំពីចំណុចខ្វះខាតនិងកាលានុវត្តភាពសម្រាប់ការស្រាវជ្រាវ នវានុវត្តន៍ និងការរៀបចំគោលនយោបាយបន្ថែម។

ឆ្លៀតក្នុងឱកាសនោះ ឯកឧត្តម **Stefan Messerer** ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាពនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា បានលើកឡើងពីសារៈសំខាន់នៃឌីជីថលូបនីយកម្មក្នុងរដ្ឋបាលសាធារណៈសម្រាប់ដំណើរការនៃការធ្វើបរិវត្តកម្មរដ្ឋាភិបាលឌីជីថល។ ឯកឧត្តមឯកអគ្គរដ្ឋទូត បានគូសបញ្ជាក់ថា បរិវត្តកម្មឌីជីថលមិនត្រឹមតែផ្លាស់ប្ដូររបៀបដែលប្រជាពលរដ្ឋប្រាស្រ័យទាក់ទងជាមួយរដ្ឋាភិបាលប៉ុណ្ណោះទេ ថែមទាំងផ្លាស់ប្ដូររបៀបដំណើរការទំនាក់ទំនងការងារផ្ទៃក្នុង និងការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋផងដែរ។ ឯកឧត្តម **Stefan Messerer** បានបន្ថែមថា តាមរយៈការលើកកម្ពស់ចំណេះដឹងផ្នែកបច្ចេកវិទ្យាឌីជីថលក្នុងវិស័យសាធារណៈ គឺជាមូលដ្ឋានគ្រឹះសម្រាប់កសាងរដ្ឋាភិបាលឌីជីថលមួយដែលមានប្រសិទ្ធភាព ការឆ្លើយតប និងផ្ដោតការយកចិត្តទុកដាក់កាន់តែច្រើនលើប្រជាពលរដ្ឋ។ ឯកឧត្តមឯកអគ្គរដ្ឋទូត ក៏បានថ្លែងអំណរគុណ និងកោតសរសើរដល់ក្រុមការងារពិសេសការគាំទ្ររបស់ **ក.ប.ទ.** សម្រាប់ការរៀបចំសន្និសីទ GovTech នេះ។


៨

ថ្លែងក្នុងឱកាសនោះដែរ ឯកឧត្តមរដ្ឋមន្ត្រី **ជា វ៉ាន់ដេត** បានមានប្រសាសន៍ថា ស្របតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ការកសាងរដ្ឋាភិបាលឌីជីថល គឺជាសកម្មភាពមួយដ៏សំខាន់សម្រាប់ប្រទេសកម្ពុជា ក្នុងការធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសាធារណៈក្នុងសេដ្ឋកិច្ចនិងសង្គមឌីជីថល។ **ឯកឧត្តមរដ្ឋមន្ត្រី** បានបន្ថែមថា សន្និសីទនេះ ជាការចាប់ផ្តើមថ្មីមួយទៀត ក្នុងកិច្ចការសកម្មភាពទាក់ទងនឹងការជំរុញកិច្ចសន្ទនាការផ្លាស់ប្តូរបទពិសោធ និងការបញ្ជ្រាបការយល់ដឹងក្នុងការចាប់យកនិងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសាធារណៈ ព្រមទាំងការស្វែងយល់ពីបញ្ហាប្រឈមនិងដំណោះស្រាយកន្លងមក ជូនគ្រប់ភាគីពាក់ព័ន្ធ ជាពិសេសរវាងក្រសួង ស្ថាប័ន ដើម្បីចូលរួមក្នុងដំណើរនៃការធ្វើបរិវត្តកម្មរដ្ឋាភិបាលឌីជីថល និងគាំទ្រដល់ការអនុវត្តគោលនយោបាយនានារបស់រាជរដ្ឋាភិបាលកម្ពុជា។ **ឯកឧត្តមរដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា យន្តការអនុវត្តនិងរចនាសម្ព័ន្ធដឹកនាំនៃដំណើរការនៃការធ្វើបរិវត្តកម្មឌីជីថលក្នុងក្រសួង ស្ថាប័ន ដើម្បីជាមូលដ្ឋានក្នុងការចេញដំណើរដែលត្រូវមានការរៀបចំអង្គភាពបរិវត្តកម្មឌីជីថលនៅតាមក្រសួង ស្ថាប័នជាចាំបាច់ ការរៀបចំតភ្ជាប់បណ្តាញឧបករណ៍ឌីជីថលនិងប្រព័ន្ធ ការរៀបចំមជ្ឈមណ្ឌលទិន្នន័យ ព្រមទាំងការរៀបចំផែនការអភិវឌ្ឍន៍ឌីជីថលនិងផែនការសកម្មភាពនៅតាមក្រសួង ស្ថាប័ន។ ថ្មីៗនេះ ការកសាងមជ្ឈមណ្ឌលទិន្នន័យជាតិ គឺជាដំណាក់កាលដ៏សំខាន់មួយសម្រាប់វិស័យសាធារណៈនិងឯកជននៅកម្ពុជា ដែលអាចផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាទំនើបមួយដែលមានសុវត្ថិភាពនិងជឿទុកចិត្តបាន  ព្រមទាំងជាកន្លែងប្រមូលផ្តុំនិងរក្សាទិន្នន័យរបស់រាជរដ្ឋាភិបាលនិងទិន្នន័យក្រុមហ៊ុនមកពីវិស័យសំខាន់ៗ តាមរយៈការផ្តល់អត្ថប្រយោជន៍ដល់ក្រសួង ស្ថាប័ន ដូចជាអធិបតេយ្យភាពទិន្នន័យ សន្សំសំចៃថវិកា និងពង្រឹងសមត្ថភាពនៃការផ្តល់សេវារបស់ខ្លួនឱ្យកាន់តែល្អប្រសើរ។ ក្រៅពីនេះ **ក.ម.ឌ.** បាននិងកំពុងពង្រឹងនិងពង្រីកហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ឌីជីថល និងគុណភាពសេវាទូរគមនាគមន៍ឱ្យកាន់តែប្រសើរឡើង ដើម្បីឆ្លើយតបទៅនឹងកំណើននៃតម្រូវការប្រើប្រាស់។ ជាមួយគ្នានេះ **ក.ម.ឌ.** បានអភិវឌ្ឍប្លាលផ្ទៀងផ្ទាត់ឯកសាររបស់រាជរដ្ឋាភិបាល verify.gov.kh ក្នុងគោលបំណងផ្តល់ភាពងាយស្រួលក្នុងការប្រើប្រាស់ និងផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃឯកសារដោយមិនតម្រូវឱ្យមានការធ្វើនីត្យានុកូលកម្មក្នុងលើឯកសារថតចម្លងក្នុងទម្រង់ជាក្រដាស ផ្តល់ទំនុកចិត្ត ចំណេញពេលវេលា និងកាត់បន្ថយការចំណាយនានា ព្រមទាំងជំរុញការធ្វើបរិវត្តកម្មឌីជីថល ស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ។

អាស្រ័យហេតុនេះ សូមសាធារណជនទាំងអស់ជ្រាបជាព័ត៌មាន។